CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ៨ ខែមិថុនាឆ្នាំ ២០២០

ទំនាក់ទំនង៖ Monique De La Garza, City Clerk, Office of the Clerk, 562.570.6101,
CityClerk@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ស្មៀនទីក្រុងបានប្រកាសពីការបើកឱ្យមានការផ្តល់មតិយោបល់ពីសាធារណៈតាមទូរស័ព្ទនៅក្នុងអងប្រជុំក្រុមប្រឹក្សាក្រុងនៃឡុងប៊ិច

ចាប់ផ្តើមពីថ្ងៃអង្គារទី ១៦ ខែមិថុនាឆ្នាំ ២០២០ ក្រុមប្រឹក្សានៃទីក្រុងឡុងប៊ិចនឹងចាប់ផ្តើមអនុញ្ញាតឱ្យមានការផ្តល់មតិយោបល់ពីសាធារណៈតាមទូរស័ព្ទលើចំណុចនីមួយៗនៅក្នុងរបៀបវារៈ។ ក្រុមប្រឹក្សាក្រុងនឹងចាប់ផ្តើមផ្លាស់ប្តូរទៅរកការបង្កើនឱកាសកាន់តែច្រើនសម្រាប់ការចូលរួមជាសាធារណៈចាប់តាំងពីបទបញ្ជាសុខភាពនិងគោលការណ៍ណែនាំទាក់ទងនឹង COVID-19 បានផ្លាស់ប្តូរច្បាប់ប្រមូលផ្តុំជាសាធារណៈនិងច្បាប់ប្រជុំសាធារណៈ។

អ្នកចុះឈ្មោះឱ្យមតិយោបល់រហូតដល់ ២០ នាក់នឹងអាចធ្វើការផ្សាយបន្តផ្ទាល់តាមទូរស័ព្ទបាន។ ប្រសិនបើអ្នកឱ្យមតិយោបល់តិចជាង ១០ នាក់ពួកគាត់ម្នាក់ៗអាចនិយាយបានដល់ទៅ ៣ នាទី។ បន្ទាប់ពីអ្នកឱ្យមតិយោបល់ចំនួន ១០ នាក់នោះបាននិយាយចប់ហើយពេលវេលានឹងកំណត់ដោយស្វ័យប្រវត្តិទៅ ៩០ វិនាទីវិញដើម្បីស្របនឹងច្បាប់ក្រុមប្រឹក្សាដែលមានស្រាប់។ ក្រុមប្រឹក្សាក្រុងនឹងបន្តកែសំរួលនិងពង្រីកការចូលជាសាធារណៈនៅប៉ុន្មានសប្តាហ៍ខាងមុខហើយបន្តអនុវត្តតាមគោលការណ៍ណែនាំរបស់លោកអភិបាលរដ្ឋដែលទាក់ទងនឹងការប្រជុំសាធារណៈ។

១០ អ្នកដំបូងដែលចុះឈ្មោះឱ្យមតិយោបល់ចំពោះចំណុចផ្សេងៗដែលមិនមាននៅក្នុងរបៀបវារៈនឹងត្រូវអនុញ្ញាតឱ្យផ្តល់មតិយោបល់តាមទូរស័ព្ទក្នុងរយៈពេល ៣ នាទីផងដែរ។ សូមចូលទៅកាន់គេហទំព័ររបស់ស្មៀនក្រុងនៅ www.longbeach.gov/cityclerk នៅថ្ងៃសុក្រទី ១២ ខែមិថុនាឆ្នាំ ២០២០ ដើម្បីស្វែងយល់បន្ថែមអំពីដំណើរការចុះឈ្មោះនិងដើម្បីចុះឈ្មោះផ្តល់មតិយោបល់តាមទូរស័ព្ទសម្រាប់ការប្រជុំនៅថ្ងៃទី ១៦ ខែមិថុនា។ សាធារណៈជូននឹងនៅតែមានជំរើសក្នុងការប្រើអេឡិកត្រូនិកដើម្បីផ្តល់មតិយោបល់ (eComment) លើចំណុចនៅក្នុងរបៀបវារៈ។ មតិយោបល់ជាលាយលក្ខណ៍អក្សរក៏អាចផ្ញើតាមអ៊ីម៉ែលទៅកាន់ cityclerk@longbeach.gov។

**អំពីទីក្រុងឡុងប៊ិច**
ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដែលផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដេលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបានទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបានការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេងហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូមតាមដានទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។

###